# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាបុណ្យព្រះយេស៊ូប្រសូតនៅតាកែវ
# ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨
## *យើងរួមរស់ជាគ្រួសារតែមួយ*

អត្ថបទទី១៖ អស ៩,១-៦
អត្ថបទទី២៖ ទត ២,១១-១៤
ដំណឹងល្អ៖ លក ២,១-១៤

បងប្អូនជាទីស្រឡាញ់!

នៅក្នុងគម្ពីរថា "**ថ្ងៃនេះខ្ញុំមានដំណឹងល្អ ដែលណែនាំឲ្យបងប្អូនទាំងអស់ពោរពេញដោយអំណរសប្បាយ**"។ ដំណឹងល្អនេះ គឺថ្ងៃនេះមានកូនង៉ែតមួយដែលបានកើតនៅក្នុងក្រោលគោ នៅក្នុងភូមិបេថ្លេហិម។ ដំណឹងល្អនេះ គឺដំណឹងល្អដែលគ្រប់យាយ ម្តាយៗដែលនៅទីនេះ ធ្លាប់មានបទពិសោធ នៅពេលយើងឆ្លងទន្លេ យើងសប្បាយចិត្ត។ មិនមែនត្រឹមតែម្តាយសប្បាយចិត្ត ឪពុកក៏សប្បាយចិត្ត លោកតាលោកយាយ និងបងប្អូនទាំងអស់គេមកមើល មកមើលកូននេះស្អាតដល់ណា។ នាងម៉ារីជាម្តាយ ឪពុកឈ្មោះយ៉ូសែប និងជាគ្រួសារមួយពោរពេញដោយក្តីសុខដោយមានកូនង៉ែតមួយយ៉ាងស្អាត នេះជាដំណឹងល្អដែលយើងចង់ចែកដល់បងប្អូនទាំងអស់។ ខ្ញុំបានចូលបុណ្យកំណើតព្រះយេស៊ូច្រើនណាស់ ខ្ញុំឃើញគ្រប់ទីកន្លែងបងប្អូនសប្បាយចិត្ត ខ្ញុំចាប់ផ្តើមនៅភ្នំពេញ នៅលើផ្លូវមុន្នីវង្សមានបងស្រីមេត្តាករុណា ដែលប្រមូលយាយតា ទាំងព្រះពុទ្ធសាសនា ទាំងឥស្លាមសាសនា ទាំងគ្រីស្តសាសនា ដើម្បីចែករំលែកអំណរសប្បាយហ្នឹង។ ខ្ញុំបានសួរដល់យាយៗ ដែលជាពុទ្ធបរិស័ទ និងឥស្លាមសាសនាថា ថ្ងៃនេះមកធ្វើអ្វី? គេថាមកគោរពបុណ្យណូអែល ប៉ុន្តែក្មេងៗគេនិយាយថាបុណ្យ Christmas។ បន្ទាប់មកមានយាយម្នាក់លើកដៃនិយាយថា "បុណ្យនៃសេចក្តីស្រឡាញ់" ជាមូលហេតុដែលយើងជុំគ្នានៅទីនេះ យើងកក់ក្តៅនៅក្នុងសេចក្តីស្រឡាញ់។

ព្រឹកមិញខ្ញុំនៅមណ្ឌលកែប្រែចិត្តគំនិត គេសប្បាយចិត្តមែនទែនពេលយើងចូលជាមួយថ្នាក់ដឹកនាំពុទ្ធសាសនាផង ឥស្លាមសាសនាផង គ្រីស្តសាសនាផង ដើម្បីចែកអំណរសប្បាយ។ អំណរសប្បាយតែមួយ២០០០ឆ្នាំមុន មានកូនង៉ែតមួយអង្គដែលបានប្រសូតហើយ និងណែនាំឲ្យពិភពលោកពីពេលនោះតទៅ មានអំណរសប្បាយថ្មីមួយ។ រៀងរាល់ឆ្នាំ មនុស្សទាំងអស់នៅក្នុងពិភពលោកទាំងមូល ស្វាគមន៍កូនង៉ែតនេះគឺព្រះបុត្រារបស់ព្រះជាម្ចាស់។ មានទេវទូតទាំងឡាយដែលចុះពីស្ថានបរមសុខមក ដើម្បីច្រៀងកោតសរសើរ "**ថ្ងៃនេះបងប្អូនអើយ! មានដំណឹងល្អមួយ សូមមនុស្សទាំងអស់ពោរពេញដោយសេចក្តីសុខសាន្ត**"។ សេចក្តីសុខសាន្តមកពីព្រះយេស៊ូ គ្រីស្តបរិស័ទទាំងអស់ជាសាក្សីនៃជំនឿដែលយើងបានទទួល និងថ្ងៃនេះយើងចែករំលែក

អំណរសប្បាយហ្នឹងជាមួយបងប្អូនទាំងអស់ អាចនិយាយថាថ្ងៃនេះ យើងជាមហាគ្រួសារមួយ។ តាមពិតនៅទីនេះ យើងមានគ្រួសារដ៏តូចមួយដែលមានឪពុក ដែលមានម្ដាយ ដែលមានកូន។ គ្រួសារនេះជាគ្រួសារមួយពោរពេញដោយភាពដ៏វិសុទ្ធ ពោរពេញដោយអំណរសប្បាយនិងសេចក្ដីសុខ។ យើងជាមហាគ្រួសារមួយ ដែលចេះទទួលស្វាគមន៍គ្នាទៅវិញទៅមក ថ្ងៃនេះ ទោះបីឪពុកម្ដាយយើងទៅឆ្ងាយ ប៉ុន្តែយើងមានគ្រួសារមួយយ៉ាងស្អាត។ យើងមានបងប្អូនដែលចេះស្វាគមន៍គ្នាទៅវិញទៅមកនៅក្នុងអំណរសប្បាយហ្នឹង។ នេះជាអត្ថន័យថ្ងៃបុណ្យព្រះយេស៊ូប្រសូត បុណ្យនៃសេចក្ដីស្រឡាញ់ ដែលណែនាំឲ្យយើងកក់ក្ដៅ ដោយដឹងថាចាប់ពីពេលនេះតទៅ នៅក្នុងជីវិតរបស់យើង យើងលែងឯកោ យើងលែងមានអារម្មណ៍ថាជីវិតរបស់ខ្ញុំត្រជាក់ណាស់ ខ្ញុំអត់មានទីពឹង ខ្ញុំអត់មានកម្លាំង ខ្ញុំអស់សង្ឃឹមហើយ។ យើងដឹងថា យើងមានគ្រួសារមួយដែលចេះលើកទឹកចិត្តគ្នាទៅវិញទៅមក ផ្ដល់សេចក្ដីសង្ឃឹម និងយើងមានសមត្ថភាពដើម្បីទីពឹងគ្នាទៅវិញទៅមកដែរ។

ខ្ញុំសូមជូនពរដល់បងប្អូនទាំងអស់ ដែលមកគោរពបុណ្យព្រះយេស៊ូប្រសូត បុណ្យនៃសេចក្ដីស្រឡាញ់ ដោយដឹងថានៅទីនេះ យើងមានគ្រួសារមួយដែលស្រឡាញ់យើង។ នៅពេលយើងទៅផ្ទះវិញ យើងនឹកឃើញអនុស្សាវរីយ៍នៅក្នុងដួងចិត្តរបស់យើង។ យប់នេះខ្ញុំសប្បាយចិត្តណាស់ និងខ្ញុំសង្ឃឹមថាមានឱកាសដើម្បីជួបគ្នាថែមទៀត និងលើកទឹកចិត្តគ្នាទៅវិញទៅមកដោយដឹងថាព្រះយេស៊ូស្រឡាញ់យើង យើងជាបុត្រធីតារបស់ព្រះជាម្ចាស់ រួមគ្នាធ្វើដំណើរដើម្បីបង្កើតមហាគ្រួសារមួយ ដែលចេះគោរពគ្នាទៅវិញទៅមកពោរពេញដោយសេចក្ដីស្រឡាញ់។

ពិតមែន ព្រះអម្ចាស់យេស៊ូប្រសូតហើយ! ណែនាំឲ្យជីវិតយើងមានសេចក្ដីសុខ សូមព្រះជាម្ចាស់ប្រទានពរដល់បងប្អូនទាំងអស់ ឲ្យបងប្អូនទាំងអស់មានកម្លាំងកាយ កម្លាំងចិត្ត មានសេចក្ដីសុខសាន្តនៅក្នុងចិត្ត និងតស៊ូតទៅទៀត ដើម្បីអនាគត ជាពិសេសអនាគតកូនៗ ឲ្យរស់នៅក្នុងសេចក្ដីសុខ និងពោរពេញដោយសុខដុមរមនានៅក្នុងសង្គមរបស់យើង។ អាម៉ែន៕